## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៥៣ កសក

រាជធានីភ្នំពេញ, ថ្ងៃទី១៤.....ខែ.មករា...ឆ្នាំ ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**<u>កម្មវត្ថុ</u>** ៖របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៥ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៥-២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៥ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៥-២០១៦ គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ មានដូចតទៅ ÷

**I. ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥** (ដូចមានតារាងជូនភ្ជាប់)÷

ផ្ទៃដីអនុវត្តបានសរុបចំនួន២.៥៦១.៩៥៧ហ.ត ស្មើនឹង៩៩,៨០ភាគរយ នៃផែនការ២.៥៦៧.១៣០ហ.ត តិចជាងឆ្នាំមុនចំនួន ២.៦១៥ហ.ត ក្នុងនោះ ការងារប្រមូលផលស្រូវរហូតដល់សប្តាហ៍នេះ សម្រេចបានលើផ្ទៃដីចំនួន ២.៤៩១.១២៩ហ.ត (សប្តាហ៍មុនចំនួន២.៤៣៤.៨០៦ហ.ត) លើសឆ្នាំមុន១៩.៧៨៥ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន៦.៨៨៥.៨៨៣តោន លើសឆ្នាំមុន ៥០.៥៣០តោន។ ទិន្នផលមធ្យម**២,៧៦៤តោន/ហ.ត** (សប្តាហ៍មុនចំនួន ២,៧៦៤ត/ហ.ត ) តិចជាងឆ្នាំមុន២គ.ក្រ/ហ.ត។ ខេត្តចំនួន១៧ គឺ ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពត កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង ឧត្តរមានជ័យ កែប ប៉ៃលិន និងត្បូងឃ្មុំ បានបញ្ចប់ការប្រមូលផលស្រូវរដូវវស្សារួចរាល់ហើយដែរ។

**II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦** ( ដូចមានតារាងជូនភ្ជាប់)÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន៥១២.៩១៤ហ.ត លើសឆ្នាំមុនចំនួន២០.៩៨២ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន១៦.៨៦៦ហ.ត ស្មើនឹង៣,២៩% និងដោយគ្រឿងយន្តចំនួន៤៩៦.០៤៨ហ.តស្មើនឹង៩៦,៧១%
- សាបបានសរុបចំនួន១.១៤១ហ.ត តិចជាងឆ្នាំមុនចំនួន២.៨២៨ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន៤៥៩.៣០២ហ.ត ស្មើនឹង១១០,០៦% នៃផែនការ៤១៧.៣២៥ហ.ត លើសឆ្នាំមុន ២៩.០៥៦ហ.ត។

**III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៥-២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន៥៧.៧២៣ហ.ត ស្មើនឹង១៣៥,១៩% នៃផែនការ៤២.៦៩៨ហ.ត លើសមុន ១២.១៥១ហ.ត។

ខ - ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន១០.៩២២ហ.ត ស្មើនឹង៥៣,៧២% នៃផែនការ២០.៣៣១ហ.ត តិចជាងឆ្នាំមុន៤៣៣ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

IV. **សេចក្ដីសន្និដ្ឋាន ÷**

ជារួមការងារប្រមូលផលស្រូវរដូវវស្សាត្រូវបានវាយតម្លៃថា បានអនុវត្តលឿនជាងឆ្នាំមុន ដែលមកទល់ពេលនេះការប្រមូលផលសម្រេចបានប្រមាណ៩៧,២៤% (ឆ្នាំមុនសម្រេចបានតែ៩៦,៣៦%ប៉ុណ្ណោះ)។ ទោះបីជួបប្រទះគ្រោះរាំងស្ងួតកណ្ដាលរដូវវស្សាក៏ដោយ ក៏ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ សម្រេចបានចំនួន៤៥៩.៣០២ហត ស្មើនឹង ១១០,០៦% នៃផែនការ៤១៧.៣២៥ហត លឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតដែរ និងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងការប្រើប្រាស់ទឹកឲ្យគត់មត់តាមសារាចរណែនាំលេខ០៩សរណន ចុះថ្ងៃទី២៣ខែធ្នូ២០១៥ របស់រាជរដ្ឋាភិបាលស្ដីពីការចាត់វិធានការថែរក្សាទឹកទុក ។ ទន្ទឹមនឹងនេះ ក្រសួងបន្តពង្រឹងវិធានការទប់ស្កាត់ការបាត់បង់បរិមាណនិងគុណភាពស្រូវរដូវវស្សាឆ្នាំ២០១៥ នៅក្នុងនិងក្រោយពេលប្រមូលផល ដើម្បីឲ្យគ្រប់អង្គភាពក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្តទូទាំងប្រទេសណែនាំដល់ប្រជាកសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឲ្យអនុវត្តក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់។

អាស្រ័យហេតុដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្ដីអនុគ្រោះ។

សូម**សម្ដេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឧកញ៉ា អ៊ុក រ៉ាប៊ុន

**ចម្លងជូន ÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
 “ដើម្បីជូនជ្រាប”
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
 “ដើម្បីជ្រាប”
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សា ឆ្នាំ ២០១៥

(គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 246,021 | 227,406 | 2.362 | 537,083 | 92.43 | 11-01-2016 |
| 02 | បាត់ដំបង | 290,056 | 265,595 | 2.670 | 709,203 | 91.57 | 13-01-2016 |
| 03 | កំពង់ចាម | 87,146 | 81,450 | 3.228 | 262,916 | 93.46 | 11-01-2016 |
| 04 | កំពង់ឆ្នាំង | 122,581 | 122,483 | 2.834 | 347,153 | 99.92 | បញ្ចប់ |
| 05 | កំពង់ស្ពឺ | 112,647 | 112,625 | 3.010 | 339,001 | 99.98 | បញ្ចប់ |
| 06 | កំពង់ធំ | 213,426 | 213,426 | 2.410 | 514,459 | 100.00 | 12-01-2016 |
| 07 | កំពត | 136,537 | 136,537 | 3.150 | 430,092 | 100.00 | បញ្ចប់ |
| 08 | កណ្តាល | 35,280 | 33,662 | 3.095 | 104,168 | 95.41 | 11-01-2016 |
| 09 | កោះកុង | 10,405 | 10,405 | 2.850 | 29,658 | 100.00 | បញ្ចប់ |
| 10 | ក្រចេះ | 32,286 | 32,286 | 2.672 | 86,263 | 100.00 | បញ្ចប់ |
| 11 | មណ្ឌលគិរី | 22,929 | 22,929 | 2.368 | 54,289 | 100.00 | បញ្ចប់ |
| 12 | ភ្នំពេញ | 11,153 | 10,095 | 2.820 | 28,468 | 90.51 | 11-01-2016 |
| 13 | ព្រះវិហារ | 83,388 | 83,388 | 2.738 | 228,303 | 100.00 | បញ្ចប់ |
| 14 | ព្រៃវែង | 268,315 | 268,315 | 2.996 | 803,983 | 100.00 | បញ្ចប់ |
| 15 | ពោធិ៍សាត់ | 108,329 | 105,393 | 3.034 | 319,762 | 97.29 | បញ្ចប់ |
| 16 | រតនគិរី | 26,018 | 26,018 | 2.031 | 52,853 | 100.00 | បញ្ចប់ |
| 17 | សៀមរាប | 186,050 | 185,220 | 2.333 | 432,160 | 99.55 | បញ្ចប់ |
| 18 | ព្រះសីហនុ | 16,614 | 16,589 | 2.750 | 45,620 | 99.85 | 13-01-2016 |
| 19 | ស្ទឹងត្រែង | 28,689 | 28,689 | 2.600 | 74,591 | 100.00 | បញ្ចប់ |
| 20 | ស្វាយរៀង | 167,946 | 167,658 | 2.650 | 444,294 | 99.83 | បញ្ចប់ |
| 21 | តាកែវ | 197,234 | 182,129 | 3.284 | 598,202 | 92.34 | 12-01-2016 |
| 22 | ឧត្តរមានជ័យ | 72,000 | 72,000 | 2.300 | 165,600 | 100.00 | បញ្ចប់ |
| 23 | កែប | 3,588 | 3,588 | 3.227 | 11,579 | 100.00 | បញ្ចប់ |
| 24 | ប៉ៃលិន | 5,001 | 4,925 | 2.633 | 12,968 | 98.48 | បញ្ចប់ |
| 25 | ត្បូងឃ្មុំ | 78,318 | 78,318 | 3.233 | 253,215 | 100.00 | បញ្ចប់ |
| សរុប | | **2,561,957** | **2,491,129** | **2.764** | **6,885,883** | **97.24** | |
| តួលេខសប្តាហ៍មុន | | **2,561,957** | **2,434,806** | **2.764** | **6,730,656** | **95.04** | |
| តួលេខឆ្នាំ២០១៤ | | **2,564,572** | **2,471,344** | **2.766** | **6,835,353** | **96.36** | |
| ប្រៀបធៀបឆ្នាំមុន | | **-2,615** | **19,785** | **-0.002** | **50,530** | **0.87** | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 13,200 | 22,993 | | - | 22,993 | 100.00 | - | - | 22,927 | 22,927 | 173.69 | បញ្ចប់ |
| 02 | បាត់ដំបង | 10,500 | 13,820 | | - | 13,820 | 100.00 | - | - | 13,806 | 13,806 | 131.49 | 13-01-2016 |
| 03 | កំពង់ចាម | 42,000 | 30,517 | 7,943 | 26.03 | 22,574 | 73.97 | 121 | 1,179 | 25,822 | 27,001 | 64.29 | 11-01-2016 |
| 04 | កំពង់ឆ្នាំង | 29,700 | 33,730 | 511 | 1.51 | 33,219 | 98.49 | 517 | 2,489 | 30,724 | 33,213 | 111.83 | 11-01-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | - | - | - | - | - | |
| 06 | កំពង់ធំ | 36,000 | 43,998 | - | - | 43,998 | 100.00 | 36 | 328 | 43,670 | 43,998 | 122.22 | បញ្ចប់ |
| 07 | កំពត | 7,000 | 9,737 | | - | 9,737 | 100.00 | - | - | 9,737 | 9,737 | 139.10 | បញ្ចប់ |
| 08 | កណ្ដាល | 53,500 | 53,054 | 1,706 | 3.22 | 51,348 | 96.78 | - | - | 52,041 | 52,041 | 97.27 | 11-01-2016 |
| 09 | កោះកុង | - | - | | - | | - | - | - | - | - | - | |
| 10 | ក្រចេះ | 14,000 | 14,302 | 2,856 | 19.97 | 11,446 | 80.03 | 366 | 4,144 | 9,194 | 13,338 | 95.27 | បញ្ចប់ |
| 11 | មណ្ឌលគិរី | - | - | | - | | - | - | - | - | - | - | |
| 12 | ភ្នំពេញ | 1,440 | 1,120 | 419 | 37.41 | 701 | 62.59 | 30 | 162 | 715 | 877 | 60.90 | 11-01-2016 |
| 13 | ព្រះវិហារ | 130 | 19 | | - | 19 | 100.00 | - | - | 15 | 15 | 11.54 | 06-01-2016 |
| 14 | ព្រៃវែង | 75,000 | 91,103 | 668 | 0.73 | 90,435 | 99.27 | - | - | 91,103 | 91,103 | 121.47 | 12-01-2015 |
| 15 | ពោធិសាត់ | 8,300 | 13,659 | | - | 13,659 | 100.00 | - | - | 13,623 | 13,623 | 164.13 | 12-01-2015 |
| 16 | រតនគិរី | - | - | | - | | - | - | - | - | - | - | |
| 17 | សៀមរាប | 20,925 | 22,680 | 150 | 0.66 | 22,530 | 99.34 | - | - | 20,985 | 20,985 | 100.29 | បញ្ចប់ |
| 18 | ព្រះសីហនុ | - | - | | - | | - | - | - | - | - | - | |
| 19 | ស្ទឹងត្រែង | 100 | 57 | | - | 57 | 100.00 | - | - | 25 | 25 | 25.00 | 12-01-2016 |
| 20 | ស្វាយរៀង | 17,850 | 19,000 | | - | 19,000 | 100.00 | - | - | 19,042 | 19,042 | 106.68 | 12-01-2016 |
| 21 | តាកែវ | 75,000 | 132,525 | 2,339 | 1.76 | 130,186 | 98.24 | - | - | 87,131 | 87,131 | 116.17 | 12-01-2016 |
| 22 | ឧត្តរមានជ័យ | 600 | 135 | | - | 135 | 100.00 | 4 | 30 | 103 | 133 | 22.17 | 12-01-2016 |
| 23 | កែប | 30 | 40 | 14 | 35.00 | 26 | 65 | - | - | 32 | 32 | 106.67 | 13-01-2016 |
| 24 | ប៉ៃលិន | 1,000 | 200 | | - | 200 | 100 | - | - | 150 | 150 | 15.00 | 13-01-2016 |
| 25 | ត្បូងឃ្មុំ | 10,500 | 10,225 | 260 | 2.54 | 9,965 | 97.46 | 67 | 670 | 9,455 | 10,125 | 96.43 | 08-01-2016 |
| **សរុប** | | **417,325** | **512,914** | **16,866** | **3.29** | **496,048** | **96.71** | **1,141** | **9,002** | **450,300** | **459,302** | **110.06** | |
| **តួលេខសប្តាហ៍មុន** | | **417,325** | **499,787** | **15,666** | **3.13** | **484,121** | **96.87** | **1,137** | **8,434** | **431,384** | **439,818** | **105.39** | |
| **តួលេខឆ្នាំមុន** | | **415,965** | **491,932** | **24,597** | **5.00** | **467,335** | **95.00** | **3,969** | **8,605** | **421,641** | **430,246** | **103.43** | |
| **ប្រៀបធៀបឆ្នាំមុន** | | **1,360** | **20,982** | **-7,731** | **-1.71** | **28,713** | **1.71** | **-2,828** | **397** | **28,659** | **29,056** | **6.63** | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 50 | - | 110 | - | 180 | 2,621 | - | - | 454 | 776 | 300 | 7 | 984 | 3,514 | 357.11 |
| 02 | បាត់ដំបង | 200 | - | 226 | - | 100 | 95 | 300 | 23 | 500 | 496 | 2,500 | 807 | 3,600 | 1,647 | 45.75 |
| 03 | កំពង់ចាម | 1,010 | 150 | 2,011 | 1,067 | 20 | 38 | 760 | 336 | 2,380 | 3,298 | 150 | 560 | 4,320 | 6,243 | 144.51 |
| 04 | កំពង់ឆ្នាំង | 500 | - | 1,065 | - | 300 | 95 | 300 | 239 | 100 | 1,787 | 2,500 | 1,805 | 3,700 | 4,991 | 134.89 |
| 05 | កំពង់ស្ពឺ | 50 | - | - | - | 200 | - | 200 | - | 100 | 82 | 500 | - | 1,050 | 82 | 7.81 |
| 06 | កំពង់ធំ | 200 | - | 242 | - | 200 | 121 | 300 | 64 | - | 369 | 500 | 18 | 1,200 | 814 | 67.83 |
| 07 | កំពត | - | - | - | - | 800 | - | 100 | - | 1,000 | - | 200 | - | 2,100 | - | - |
| 08 | កណ្តាល | 3,000 | - | 3,922 | 3,707 | 300 | 49 | 200 | 86 | 3,000 | 3,596 | 700 | 3,519 | 7,200 | 11,172 | 155.17 |
| 09 | កោះកុង | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 10 | ក្រចេះ | 500 | - | 4,772 | 4,623 | 100 | - | 100 | 64 | 100 | 454 | 300 | 45 | 1,100 | 5,335 | 485.00 |
| 11 | មណ្ឌលគិរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 12 | ភ្នំពេញ | 285 | - | 21 | - | - | 2 | - | 3 | 600 | 50 | - | 4 | 885 | 80 | 9.04 |
| 13 | ព្រះវិហារ | - | - | - | - | - | - | - | - | - | 304 | - | - | - | 304 | - |
| 14 | ព្រៃវែង | 1,000 | - | 874 | 874 | 100 | 4 | 200 | - | 500 | 641 | 1,200 | 2,328 | 3,000 | 3,847 | 128.23 |
| 15 | ពោធិ៍សាត់ | 200 | - | 176 | 5 | 400 | 963 | 350 | 32 | 350 | 367 | 350 | 53 | 1,650 | 1,591 | 96.42 |
| 16 | រតនគិរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 17 | សៀមរាប | 500 | - | 476 | - | 500 | 2,790 | 500 | 230 | 900 | 933 | 1,200 | 2,150 | 3,600 | 6,579 | 182.75 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | - | - | - | 26 | - | - | - | 26 | - |
| 19 | ស្ទឹងត្រែង | - | - | 158 | - | - | - | - | 25 | 100 | 185 | 100 | 150 | 200 | 518 | 259.00 |
| 20 | ស្វាយរៀង | 100 | 38 | - | - | 100 | 385 | 200 | 86 | 150 | 954 | 350 | - | 900 | 1,425 | 158.33 |
| 21 | តាកែវ | - | - | 85 | - | 500 | 43 | 200 | 67 | 800 | 440 | 500 | 64 | 2,000 | 699 | 34.95 |
| 22 | ឧត្តរមានជ័យ | 109 | - | 107 | - | 24 | - | 6 | 23 | - | 118 | 100 | 99 | 239 | 347 | 145 |
| 23 | កែប | - | - | 109 | 3 | 300 | 11 | 100 | 83 | 200 | 100 | - | - | 600 | 303 | 50.50 |
| 24 | ប៉ៃលិន | - | - | - | - | 50 | - | - | - | - | - | 400 | - | 450 | - | - |
| 25 | ត្បូងឃ្មុំ | 2,800 | - | 6,230 | 5,880 | - | 14 | 300 | 415 | 570 | 1,000 | 250 | 547 | 3,920 | 8,206 | 209.34 |
| | **សរុប** | **10,504** | **188** | **20,584** | **16,159** | **4,174** | **7,231** | **4,116** | **1,776** | **11,804** | **15,976** | **12,100** | **12,156** | **42,698** | **57,723** | **135.19** |
| | **តួលេខសប្តាហ៍មុន** | **10,504** | **188** | **20,120** | **16,156** | **4,174** | **6,406** | **4,116** | **1,667** | **11,804** | **15,204** | **12,100** | **11,724** | **42,698** | **55,121** | **129.10** |
| | តួលេខឆ្នាំមុន | 10,504 | 188 | 14,841 | 11,351 | 4,174 | 12,535 | 4,116 | 1,885 | 11,804 | 11,775 | 12,100 | 4,536 | 42,698 | 45,572 | **106.73** |
| | ប្រៀបធៀបឆ្នាំមុន | - | - | 5,743 | 4,808 | - | -5,304 | - | -109 | - | 4,201 | - | 7,620 | - | 12,151 | **28.46** |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | - | - | - | - | - | - | 45 | - | - | - | - | - | 45 | - |
| 02 | បាត់ដំបង | 100 | 35 | - | - | 160 | 111 | 27 | 24 | | - | | - | 287 | 170 | 59.23 |
| 03 | កំពង់ចាម | 790 | 701 | - | - | 30 | - | 360 | 296 | - | - | 3,380 | 3,544 | 4,560 | 4,541 | 99.58 |
| 04 | កំពង់ឆ្នាំង | 100 | 92 | - | - | 100 | 792 | 100 | 61 | - | 8 | 50 | 65 | 350 | 1,018 | 290.86 |
| 05 | កំពង់ស្ពឺ | - | - | - | - | - | - | 120 | - | - | - | - | - | 120 | - | - |
| 06 | កំពង់ធំ | - | 116 | 1,000 | - | - | 7 | - | 2 | - | - | - | - | 1,000 | 125 | 12.50 |
| 07 | កំពត | 250 | - | - | - | - | - | 200 | - | - | - | 100 | - | 550 | - | - |
| 08 | កណ្តាល | 500 | 8 | - | 25 | - | 18 | 800 | 537 | - | 11 | - | - | 1,300 | 599 | 46.08 |
| 09 | កោះកុង | - | - | - | - | - | - | - | - | | - | - | - | - | - | - |
| 10 | ក្រចេះ | 100 | 168 | - | - | 100 | - | 50 | 74 | | - | 50 | 724 | 300 | 966 | 322.00 |
| 11 | មណ្ឌលគិរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 12 | ភ្នំពេញ | - | - | - | - | - | - | - | 3 | | - | | - | - | 3 | - |
| 13 | ព្រះវិហារ | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 14 | ព្រៃវែង | 400 | 240 | - | - | 200 | 2 | 100 | 178 | - | - | - | - | 700 | 420 | 60.00 |
| 15 | ពោធិ៍សាត់ | 600 | 26 | - | 82 | 200 | 196 | 1,000 | 65 | - | - | - | - | 1,800 | 369 | 20.50 |
| 16 | រតនគិរី | - | - | - | - | - | - | - | - | | - | | - | - | - | - |
| 17 | សៀមរាប | - | - | - | 630 | 800 | 15 | 400 | 130 | 80 | - | - | - | 1,280 | 775 | 60.55 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | - | - | | - | - | - | - | - | - |
| 19 | ស្ទឹងត្រែង | 200 | 65 | - | - | - | - | - | - | | - | 30 | - | 230 | 65 | - |
| 20 | ស្វាយរៀង | - | - | - | - | - | - | 50 | 186 | | - | - | - | 50 | 186 | 372.00 |
| 21 | តាកែវ | - | 22 | - | - | - | - | 100 | 50 | - | - | - | - | 100 | 72 | 72.00 |
| 22 | ឧត្តរមានជ័យ | 184 | 75 | 173 | - | 1,199 | 55 | 408 | 29 | - | - | - | - | 1,964 | 159 | 8 |
| 23 | កែប | 100 | 29 | - | - | - | - | - | 6 | | - | | - | 100 | 35 | 35.00 |
| 24 | ប៉ៃលិន | 50 | - | - | - | - | - | - | - | | - | | - | 50 | - | - |
| 25 | ត្បូងឃ្មុំ | 250 | 124 | - | - | - | - | 20 | 20 | | - | 5,320 | 1,230 | 5,590 | 1,374 | 24.58 |
| **សរុប** | | **3,624** | **1,701** | **1,173** | **737** | **2,789** | **1,196** | **3,735** | **1,706** | **80** | **19** | **8,930** | **5,563** | **20,331** | **10,922** | **53.72** |
| **តួលេខសប្តាហ៍មុន** | | **3,624** | **1,685** | **1,173** | **737** | **2,789** | **1,129** | **3,735** | **1,599** | **80** | **19** | **8,930** | **5,563** | **20,331** | **10,732** | **52.79** |
| តួលេខឆ្នាំមុន | | 3,624 | 1,671 | 1,173 | 22 | 2,789 | 1,115 | 3,735 | 1,351 | - | 22 | 8,930 | 7,174 | 20,251 | 11,355 | 56.07 |
| ប្រៀបធៀបឆ្នាំមុន | | - | 30 | - | 715 | - | 81 | - | 355 | 80 | -3 | - | -1,611 | 80 | -433 | -2.35 |

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ